ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង Working Together for Positive Change

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

NGOF:..១២០..../NDP/២០២០

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**
**ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** គោរពផ្ញើជូននូវ សេចក្តីថ្លែងគោលជំហរ និងធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិលលើខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពី សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ តាងនាមឱ្យក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល ដែលសម្របសម្រួលដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា យើងខ្ញុំសូមសម្តែងនូវការអបអរសាទរ និងកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសរដ្ឋសភាដែលបានបង្កើតសមិទ្ធផលដ៏ត្រចះត្រចង់ក្នុងទសវត្សរ៍ចុងក្រោយនេះ បើទោះបីជាពិភពលោកកំពុងតែជួបនូវវិបត្តិនៃការរីករាលដាលនូវជំងឺកូវីដ១៩ ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែអាចគ្រប់គ្រងបាននូវស្ថិរភាពសេដ្ឋកិច្ចគួរជាទីមោទនៈ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់រដ្ឋសភា ដែលបានអញ្ជើញវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ស្តីពី ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុ ដើម្បីធ្វើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលគ្រោងធ្វើឡើងកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ នៅវិមានរដ្ឋសភា តែត្រូវបានពន្យាពេលវិញក្រោយពីមានព្រឹត្តិការណ៍០៣វិច្ឆិកា។

យើងខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាពញាចក្រី** មេត្តាជ្រាបថា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងសមាជិកក្រុមការងារថវិកាជាតិ បានពិនិត្យមើលឯកសារព្រាងដោយយកចិត្តទុកដាក់បំផុត។ ជាលទ្ធផលក្រុមការងារ បានចងក្រងជាមតិយោបល់ទៅលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដូចដែលបានភ្ជាប់ជូនមកជាមួយនេះ ជូនដល់រដ្ឋសភាដើម្បីជាធាតុចូល ក្នុងការជជែកពិភាក្សាជាមួយស្ថាប័នរាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាពញាចក្រី** មេត្តាពិនិត្យ និងទទួលយកនូវមតិយោបល់ធាតុចូលនេះ ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាពញាចក្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃសុក្រ ៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០
ជ.ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល
**នាយកប្រតិបត្តិ**

NGO FORUM ON CAMBODIA

**បណ្ឌិត តឹក វណ្ណារ៉ា**

**សូមភ្ជាប់ជូនជាមួយមកនូវ៖**
- សេចក្តីថ្លែងគោលជំហរ និងធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិលលើខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ចំនួន ០១ច្បាប់

**ចម្លងជូន៖**
- ឯកឧត្តម ឡេង ប៉េងឡុង អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា
- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សេចក្តីថ្លែងគោលជំហរ និងធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិល លើខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

តាងនាមក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអបអរសាទរដល់ រដ្ឋសភាជាតិ និងរាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយជោគជ័យនាពេលកន្លងមក។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលតែងតែអញ្ជើញអង្គការសង្គមស៊ីវិល ចូលរួមនៅក្នុងសិក្ខាសាលាស្តីពីក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនាពេលកន្លងមក ព្រមទាំងបានបើកឱកាសនិងស្វាគមន៍នូវរាល់ការផ្តល់មតិយោបល់ធាតុចូល និងអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឲ្យក្របខ័ណ្ឌគោលនយោបាយ និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ មានភាពគ្រប់ជ្រុងជ្រោយ និងមានការចូលរួម។ ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលតែងតែយកចិត្តទុកដាក់លើការងារនេះជាប្រចាំ និងបានចូលរួមផ្តល់នូវមតិយោបល់ដែលជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋ ជាមួយរដ្ឋសភាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចការដ៏មានសារៈសំខាន់នេះ។

អង្គការសង្គមស៊ីវិល សូមធ្វើការវាយតម្លៃខ្ពស់របស់រាជរដ្ឋាភិបាល ជាពិសេសស្ថាប័ន ក្រសួងសាមី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងផ្សព្វផ្សាយនូវ ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២១ ដែលរដ្ឋសភាជាតិ គ្រោងនឹងដាក់ពិភាក្សា និងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។

អង្គការសង្គមស៊ីវិល សំណូមពរឱ្យរាជរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយ និងផ្តល់សេចក្តីព្រាងច្បាប់ថវិកាពេញលេញសម្រាប់ប្រជាពលរដ្ឋ និងបង្កើតឱ្យមានកិច្ចពិភាក្សា រវាងរដ្ឋសភា ក្រសួង ប្រជាពលរដ្ឋ និង អង្គការសង្គមស៊ីវិល ដើម្បីបន្តចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងតម្លាភាពថវិកាដែលជាផ្នែកមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបង្កើតយន្តការសាកល្បងដើម្បីចូលរួមជាសាធារណៈ ក្នុងអំឡុងពេលកសាងផែនការថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលគួរបង្កើតវេទិកា ឬយន្តការទៀងទាត់មួយសម្រាប់សាធារណជនចូលរួមវិភាគទានជាបដិមតិ ក្នុងន័យស្ថាបនាក្នុងដំណើរការត្រួតពិនិត្យការអនុវត្តថវិកា ដែលបានអនុម័តរួច។

ក្រុមការងារថវិកាជាតិនៃអង្គការសង្គមស៊ីវិល សូមអនុញ្ញាតលើកយកគោលជំហរ ធាតុចូលសំខាន់ៗនិងអនុសាសន៍ដែលចេញមកពីការសិក្សាស្រាវជ្រាវ វិភាគនានា[1] របស់ទីប្រឹក្សាឯករាជ្យ និងក្រុមការងារ ជូនដល់រដ្ឋសភាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចខាងក្រោម៖

---

[1] ការសិក្សាវិភាគលើខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដែលចេញផ្សាយលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៣ខែតុលា ឆ្នាំ២០២០ កន្លងទៅថ្មីៗនេះ និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**ជារួមយើងសង្កេតឃើញថា ថវិកាជាតិឆ្នាំ២០២១ នឹងមានការថយចុះជាមធ្យមប្រមាណ៤% បើប្រៀបធៀបនឹងច្បាប់ឆ្នាំ២០២០។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថវិកាថ្នាក់ក្រោមជាតិធ្លាក់ចុះដល់ទៅ២២.៥% ដែលជាការព្រួយបារម្ភ ថាការអភិវឌ្ឍនៅមូលដ្ឋានភូមិ ឃុំ ស្រុកនឹងមានភាពយឺតយ៉ាវ ហើយគម្រោងវិនិយោគឃុំសង្កាត់មួយចំនួននឹងត្រូវពន្យារ។**

អង្គការសង្គមស៊ីវិលសាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនចំណូលសរុបថវិការដ្ឋ ឬថវិកាជាតិ។ ទោះបីជាយ៉ាងណាសង្គមស៊ីវិលនៅតែមានការបារម្ភក្នុងការប្រមូលចំណូលសម្រេចទៅតាមផែនការ។ ដូចនេះសង្គមស៊ីវិល **លើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលគិតគូរឱ្យបានហ្មត់ចត់ ក្នុងការធានាបាននូវការប្រមូលចំណូលនោះប្រកបដោយការទទួលខុសត្រូវខ្ពស់។ ចំណូល និងចំណាយ គឺត្រូវតែធ្វើឡើងឱ្យមានសមតុល្យគ្នា ព្រោះបើមិនដូច្នេះទេនឹងធ្វើឱ្យរដ្ឋាភិបាល បង្កើនការខ្ចីពីបរទេសកាន់តែច្រើនថែមទៀត ដែលគ្រោងថានឹងមានការកើនឡើង ក្នុងកម្រិត ១ ៥០០ លាន SDR គឺកើនឡើង ១០០ លាន SDR ធៀបនឹងឆ្នាំ ២០២០។ សង្គមស៊ីវិលសូមស្នើក្រសួងស្ថាប័នទាំងអស់ចូលរួមកាត់បន្ថយនូវចំណាយណាដែលមិនចាំបាច់ និងលើកទឹកចិត្ត ឱ្យរដ្ឋាភិបាលភៀរគរសង្គមស៊ីវិល និងវិស័យឯកជនចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍។ អង្គការសង្គមស៊ីវិល សូមស្នើរាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណាក្នុងការបន្ថយចំណាយលើវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយគួរតែយកចិត្តទុកដាក់លើវិស័យសេដ្ឋកិច្ច និងវិស័យសង្គមឱ្យបានច្រើន។**

សង្គមស៊ីវិល គាំទ្រចំពោះ បទអន្តរាគមន៍ទាក់ទងនឹងជំងឺកូវីដ ១៩ ក្នុងនោះក៏សូមស្នើរាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាល **ជួយគិតគូរបន្ថែមទៀតលើជំងឺមិនឆ្លង។** ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាល និងរដ្ឋសភា **ពិចារណាលើការវិភាជថវិកាសម្រាប់វិស័យអប់រំ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ គួរត្រូវបានបង្កើនលើសពីឆ្នាំមុនៗ** ដោយបង្កើត និងបង្កើនអន្តរកម្មរវាងវិស័យទាំងពីរនេះ ដើម្បីវិស័យនេះមានលទ្ធភាពបង្កើតកម្មវិធីសិក្សា និងវិធីសាស្ត្ររៀននិងបង្រៀនថ្មីៗ ឆ្លើយតបនឹងតម្រូវការ លើកកម្ពស់ការត្រួតពិនិត្យវាយតម្លៃ និងផ្តល់កិច្ចគាំពារបច្ចេកទេសនានាបន្ថែម។

អង្គការសង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាល ធ្វើចំណាត់ថ្នាក់សម្រាប់ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ជាពិសេសផ្តោតលើការប្រើប្រាស់ថវិកាសម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ស.ក និងគ.ក.ន.ក ក្នុងការផ្តល់សេវាសង្គមសម្រាប់ប្រជាពលរដ្ឋជាពិសេសស្ត្រី ជនមានពិការភាព និងកុមារ។ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គួរផ្តោតលើការបំពេញមុខងាររបស់មន្ទីរជំនាញ ដែលបានទទួលការផ្ទេរមុខងារពីថ្នាក់ជាតិផងដែរ។ ជាមួយគ្នានេះ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់អាទិភាពផងដែរ ចំពោះការអនុវត្តមុខងាររបស់សេវាច្រកចេញតែមួយប្រកបដោយគុណភាព និងបែងចែកថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមជំហានទី២ ដោយជោគជ័យនិងពង្រឹងភាពជាម្ចាស់របស់រដ្ឋាភិបាល។ សូមបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាពិសេសជនដែលងាយរងគ្រោះនៅក្នុងដំណើររៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានប្រសើរឡើង និងធានាបាន គណនេយ្យភាពនៅក្នុងការផ្តល់នូវសេវាសាធារណៈ។

ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច យើងខ្ញុំសូមស្នើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្យាករណ៍ឱ្យបានសុក្រិត ជៀសវាងការធ្វើនិយ័ត ឬវិចារណកម្មច្រើនដង។ ខាងក្រោមនេះគឺជាសេចក្តីស្នើលម្អិត៖

១. ការប្រមូលចំណូល៖ រដ្ឋគួរតែប្រមូលចំណូលឲ្យអស់លទ្ធភាព ឈរលើគោលការណ៍យុត្តិធម៌ និងសមធម៌ ដើម្បីកាត់បន្ថយវិសមភាពសង្គម និងរក្សាបាននូវស្ថេរភាពកំណើនសេដ្ឋកិច្ច។ ការបង្កើន នូវពន្ធអាករបន្ថែមលើផលិតផលដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពដូចជាគ្រឿងស្រវឹង និងភេសជ្ជៈដែលមានរសជាតិផ្អែមហើយ វិភាជទៅលើវិស័យសុខាភិបាល។

២. រាជរដ្ឋាភិបាលត្រូវត្រៀមខ្លួនឲ្យបានរួចរាល់ក្នុងការរៀបចំនូវវិស័យដែលទ្រទ្រង់កំណើនសេដ្ឋកិច្ច ដូចជាវិស័យទេសចរណ៍ ដោយបន្ថែមនូវមុខងារឲ្យបានច្រើនដូចជាទេសចរណ៍សិប្បនិមិត្ត ធម្មជាតិ និងវប្ប

ធម៌ ជាដើម។ វិស័យកសិកម្ម ក្រសួងពាក់ព័ន្ធគួរមានយន្តការក្នុងការផលិតដើម្បីឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដែលក្នុងនោះ កសិឧស្សាហ៍កម្មគួរតែត្រូវបានយកចិត្តទុកដាក់។ បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយយកចិត្តទុកដាក់បន្ថែម និងលើកទឹកចិត្តប្រជាពលរដ្ឋផលិតឱ្យបានច្រើន ព្រមទាំងគិតគូរដល់ការបង្កើនប្រព័ន្ធស្រោចស្រព និង ចែកពូជដល់កសិករ។

៣. ការចំណាយ៖ សូមស្នើរាជរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការកាត់បន្ថយនូវចំណាយដែលមិនចាំបាច់ ឬផ្លាស់ប្តូរនូវរបៀបធ្វើការដូចជា៖ ការចុះជួបកម្មករ កម្មការនី គួរផ្តល់សិទ្ធិដល់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការធ្វើកិច្ចការងារនេះ ជាជាងចំណាយក្នុងការរៀបចំវេទិកាធំៗដែលធ្វើឱ្យមានការចំណាយច្រើន។ ត្រូវធានាថា រាល់ការចំណាយគឺឆ្លើយតប ទៅនឹងគោលនយោបាយដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជាវិស័យសុខាភិបាល លើជំងឺឆ្លង និងជំងឺមិនឆ្លង។

៤. រាជរដ្ឋាភិបាលគួរផ្តោតសំខាន់លើវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដើម្បីឆ្លើយតបតម្រូវការអភិវឌ្ឍន៍ ជាពិសេសតម្រូវការទីផ្សារការងារ និងនវានុវត្តអប់រំប្រកបដោយបរិយាបន្ន ដោយធានាបាននូវបរិយាប័ន្នសង្គម ដូចជា ក) ពង្រឹងលើប្រព័ន្ធសុវត្ថិភាព និងកិច្ចគាំពារសង្គម ខ) កាត់បន្ថយការរំលោភបំពានសិទ្ធិស្ត្រី និងសិទ្ធិកុមារ ការរើសអើងនៃពិការភាព និងអត្តសញ្ញាណយេនឌ័រ។

៥. ពង្រឹងការឆ្លើយតបឲ្យមានប្រសិទ្ធភាពខ្ពស់ផ្នែកសុខាភិបាល ក) អាទិភាពលើវិស័យអប់រំពិសេសការឆ្លើយតបទាន់សភាពការបន្ទាប់ពីបញ្ចប់ការរីករាលដាលនៃជំងឺកូវីដ-១៩ លើកកម្ពស់ និងរក្សាឲ្យបាននូវបទដ្ឋានស្តង់ដារសុវត្ថិភាព អនាម័យ និងទឹកស្អាត នៅតាមសាលារៀន ខ) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដែលឆ្លើយតបទីផ្សារនានាបច្ចុប្បន្ន សម្រាប់ការប្រកួតប្រជែងនាពេលអនាគត។

៦. ទិដ្ឋភាពបំណុល និងកម្ចីបរទេស៖ ស្ថានភាពបំណុល៖ រដ្ឋាភិបាលមានបានប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ ដែលក្នុងនោះមានដាក់ចំណុចមួយគឺ ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាពគណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។ យ៉ាងណាសង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាលជាពិសេសគឺក្រសួងសេដ្ឋកិច្ច និងអ្នកត្រួតពិនិត្យការអនុវត្តគម្រោងយកចិត្តទុកដាក់បន្ថែមទៀតលើការអនុវត្តគម្រោងទាំងអស់ដោយស្មារតីមនសិការជាតិ។ សូមស្នើរាជរដ្ឋាភិបាលប្រើប្រាស់នូវកម្ចីនេះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដោយធានាឲ្យបាននូវការចូលរួមដឹងឮពីគ្រប់ភាគីពាក់ព័ន្ធជាពិសេសទាក់ទងនឹងការពង្រឹងការងារលទ្ធកម្មសាធារណៈ។ កម្ចីបរទេសគួរតែផ្តល់អាទិភាពមិនត្រឹមតែលើរចនាសម្ព័ន្ធរូបវ័ន្តប៉ុណ្ណោះទេ តែគួរតែត្រូវពិចារណាផងដែរទៅលើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសង្គមដូចជាការកសាងជំនាញវិជ្ជាជីវៈដល់កម្មករ និងពិពិធកម្មសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលគួរពិភាក្សា និងស្នើសុំការពន្យា ពេលសងដល់ធនាគារផ្សេងៗដែលរដ្ឋាភិបាលបានខ្ចី។

៧. បញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩៖ រដ្ឋាភិបាលគួរគិតគូរបន្ថែមលើការយកចិត្តទុកដាក់ពីផលប៉ះពាល់របស់ប្រជាពលរដ្ឋជាពិសេសអ្នកធ្វើការក្រៅប្រព័ន្ធ។ ជំរុញឱ្យមានផែនការច្បាស់លាស់ក្នុងការអភិវឌ្ឍធនធានមនុស្សផ្តោត លើជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ជាពិសេសក្នុងដំណាក់កាលនៃការរីករាតត្បាតនៃជំងឺកូវីដ ១៩ ដូចជាជម្រុញការបង្កើតនិងលើកកម្ពស់ ការបង្រៀន និងរៀនតាមបែប ឌីជីថល ជាដើម។

៨. ការប៉ះពាល់នៃការបាត់ ការអនុគ្រោះពន្ធលើមុខទំនិញមួយចំនួនក្នុងក្របខ័ណ្ឌទំនិញគ្រប់បែបយ៉ាងលើកលែងសព្វាវុធ (EBA) ធ្វើឲ្យប៉ះពាល់ដល់វិស័យការងារ និងចំណូលរបស់ពលរដ្ឋ ដែលសូមស្នើឲ្យ

រាជរដ្ឋាភិបាល ជំរុញឲ្យមានវិធានការឆ្លើយតបចំពោះកត្តាប្រឈម ដូចជាផ្តល់ប្រាក់ឧបត្ថម្ភ បង្កើតការងារ គៀរគរកការវិនិយោគបន្ថែម។

៩. រាជរដ្ឋាភិបាល គួរបន្តយកចិត្តទុកដាក់បន្ថែមទៀត លើប្រសិទ្ធភាពនៃការបែងចែកថវិកាថ្នាក់ក្រោមជាតិ ដោយសារមានការថយចុះដល់ទៅ២២.៥% ដែលជាការព្រួយបារម្ភ ថាការអភិវឌ្ឍនៅមូលដ្ឋានភូមិ ឃុំ ស្រុកនឹងមានភាពយឺតយ៉ាវ ហើយគម្រោងវិនិយោគឃុំសង្កាត់មួយចំនួននឹងត្រូវពន្យារ ព្រមទាំងពង្រឹងនូវយន្តការចំណាយឲ្យមានប្រសិទ្ធភាព និងតម្លាភាព ដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន ស្របតាមគោលនយោបាយអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងកម្មវិធីគណនេយ្យភាពសង្គម ដំណាក់កាលទី២។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមរដ្ឋសភាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលយកនូវធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិល ដើម្បីពិចារណា ដោយសេចក្តីអនុគ្រោះ។ ក្រុមការងារយើងខ្ញុំ ត្រៀមខ្លួនជាស្រេច ក្នុងការជួបពិភាក្សា ផ្លាស់ប្តូរមតិយោបល់ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ឲ្យបានរីកចម្រើនឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

សូម មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**<u>បញ្ជាក់៖</u>** ការវិភាគលម្អិតមានជូនភ្ជាប់មកជាមួយ។
សូមអរគុណ។

ថ្ងៃសុក្រ ៥ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២០

តំណាងក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ

**១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា**
**២. អង្គការតម្លាភាពកម្ពុជា**
**៣. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ**
**៤. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**
**៥. អង្គការស្តារកម្ពុជា**
**៦. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន**
**៧. អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល**
**៨. គណកម្មការសម្របសម្រួលសកម្មភាពសុខភាព**
**៩. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា**
**១០. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា**
**១១. អង្គការអុកស្វាមកម្ពុជា**

# ការវិភាគរបស់ក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិល លើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

**<u>សេចក្តីបញ្ជាក់៖</u>** ការវិភាគនេះគឺធ្វើឡើងដោយផ្អែកលើ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ចេញផ្សាយលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០២០ ដូច្នេះការវិភាគ នឹងមិនឆ្លុះបញ្ចាំងថវិកាលម្អិត ដែលមិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ។

## ១. សរុបចំណាយថវិការដ្ឋ

យោងតាមខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ បានឱ្យដឹងថា ការចំណាយសរុបថវិការដ្ឋ ឆ្នាំ២០២១ ត្រូវបានគ្រោងចំនួន ៣២.០០៩.៧៤២ លានរៀល ត្រូវជា ២៧,១៤% នៃផសស គឺមានការថយចុះ ៤,០% ធៀបនឹងច្បាប់ឆ្នាំ២០២០។ ក្នុងនោះ ចំណាយចរន្តថវិកាជាតិគ្រោងមានចំនួន ១៨.៧៥១.០៤១លានរៀល ត្រូវជា ១៥,៩០% នៃផសស គឺថយចុះ ៥,៤% ធៀបនឹងច្បាប់ឆ្នាំ២០២០។ ការចំណាយមូលធនថវិការដ្ឋគ្រោងមានចំនួន ១៣.២៥៨.៧០១លានរៀល ត្រូវជា ១១,២៤% នៃផសស គឺថយចុះ ១,៩% ធៀបនឹងច្បាប់ឆ្នាំ២០២០។

| ចំណាយថវិកា (ឯកតាលានរៀល) | ២០២០ | | ២០២១ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ** | **33,339,633** | **30.13%** | **32,009,742** | **27.14%** | **-4.0%** |
| · ថ្នាក់ជាតិ | 31,095,855 | 28.10% | 30,491,336 | 25.85% | -1.9% |
| · ថ្នាក់ក្រោមជាតិ | 3,329,236 | 3.01% | 2,578,856 | 2.19% | -22.5% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **19,818,306** | **17.91%** | **18,751,041** | **15.90%** | **-5.4%** |
| **១.១. ថ្នាក់ជាតិ** | **18,036,884** | **16.30%** | **17,446,841** | **14.79%** | **-3.3%** |
| ·បន្ទុកបុគ្គលិក | 8,539,752 | 7.72% | 8,565,574 | 7.26% | 0.3% |
| ·ក្រៅបន្ទុកបុគ្គលិក | 9,497,132 | 8.58% | 8,881,267 | 7.53% | -6.5% |
| **១.២. ថ្នាក់ក្រោមជាតិ** | **2,866,880** | **2.59%** | **2,364,650** | **2.00%** | **-17.5%** |
| ·បន្ទុកបុគ្គលិក | 599,128 | 0.54% | 761,015 | 0.65% | 27.0% |
| ·ក្រៅបន្ទុកបុគ្គលិក | 2,267,752 | 2.05% | 1,603,635 | 1.36% | -29.3% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **13,521,327** | **12.22%** | **13,258,701** | **11.24%** | **-1.9%** |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6,362,215 | 5.75% | 6,607,861 | 5.60% | 3.9% |
| + ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ | 462,356 | 0.42% | 214,206 | 0.18% | -53.7% |
| - ការទូទាត់ប្រាក់ខ្ចី | 1,105,922 | 1.00% | 1,185,190 | 1.00% | 7.2% |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 6,053,190 | 5.47% | 5,465,650 | 4.63% | -9.7% |

ប្រភព៖ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ច្បាប់ថវិកាឆ្នាំ ២០២១គឺនៅតែផ្តោតខ្លាំងនៅថ្នាក់កណ្តាលនៅឡើយ ដែលកត្តានេះនឹងជះឥទ្ធិពលដល់ការអនុវត្តកំណែទំរង់ហិរញ្ញវត្ថុសាធារណៈនៅដំណាក់កាលទី ៤ ជាពិសេស សម្មិតិកម្មផ្សារភ្ជាប់ថវិកា។ អង្គការសង្គមស៊ីវិលសាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនចំណូលសរុបថវិការដ្ឋ ឬចំណូលសរុបថវិកាជាតិ។ ទោះបីជាយ៉ាងណាសង្គមស៊ីវិលនៅតែមានការបារម្ភក្នុងការប្រមូលចំណូលដើម្បីសម្រេចទៅតាមផែនការ។ ដូចនេះ សង្គមស៊ីវិលលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលគិតគូរឱ្យបានហ្មតចត់ក្នុងការធានាបាន នូវការប្រមូលចំណូលនោះប្រកបដោយការទទួលខុសត្រូវខ្ពស់។

## ២. ការចំណាយថវិកាតាមវិស័យ

ដូចដែលបានថែងក្នុងខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ យើងពិនិត្យឃើញថាការគ្រោងថវិកា លើវិស័យសង្គមកិច្ច មានទំហំច្រើនជាងគេ ដែលមានថវិកាចំនួន ៧.៨២៤.៩០៦លានរៀល បើទោះបីជាមានការថយចុះ ០,៦% ធៀបនឹងច្បាប់ឆ្នាំ២០២០ក៏ដោយ។ វិស័យដែលអាទិភាពបន្ទាប់គឺ វិស័យសេដ្ឋកិច្ច ដែលបានគ្រោងថវិកាចំនួន ៦.៤២៥.៧៨៩ លានរៀល បើទោះបីជាមានការថយចុះ១២,៣% ធៀបនឹងច្បាប់ឆ្នាំ២០២០។ ក្នុងនោះដែរ វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ត្រូវបានគ្រោងថវិកាចំនួន ៤.៧៦៩.៥៥៩លានរៀល បើទោះបីជាមានការថយចុះ ០,៥% ធៀបនឹងច្បាប់ឆ្នាំ២០២០ ស្របពេលដែលវិស័យរដ្ឋបាលទូទៅត្រូវបានគ្រោងថវិកាតិចជាងគេ គឺចំនួន ១.៩៧២.១៩៧លានរៀល បើទោះបីជាមានការថយចុះ ២១,៥% ធៀបនឹងច្បាប់ឆ្នាំ២០២០។




ប្រភព៖ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងបរិការណ៍នេះ **អង្គការសង្គមស៊ីវិល សូមស្នើរាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណាក្នុងការបន្ថយចំណាយលើវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈដោយគួរតែយកចិត្តទុកដាក់ខ្លាំងលើវិស័យសេដ្ឋកិច្ច និងវិស័យសង្គមដែលរងផលប៉ះពាល់ដោយជម្ងឺរាតត្បាតកូវីដ១៩ ឱ្យបានច្រើន។**

## ៣. ថវិកាវិភាជលើវិស័យសង្គមកិច្ច




ប្រភព៖ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដល់ ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ថវិកាវិស័យអប់រំ

ថវិកាវិស័យអប់រំមាននិន្នាការធ្លាក់ចុះបើប្រៀបធៀបលើការវិភាជចរន្តពី១៨,៣%នៅឆ្នាំ២០១៧មក១៧,៨% នៅឆ្នាំ២០១៨ មក១៧,៥% នៅឆ្នាំ២០១៩ ១៧.៨% នៅឆ្នាំ២០២០ និងប្រមាណ ១៨% នៅឆ្នាំ២០២១ ធៀបនឹងថវិកាជាតិចរន្ត។ ទោះបីជាថវិកាវិភាជនេះមានកម្រិតខ្ពស់ជាងក្រសួងនានាក្នុងវិស័យសង្គមកិច្ច ប៉ុន្តែនិន្នាការថយចុះលើការវិភាជធ្វើឲ្យទំហំថវិកាគ្រោងសម្រាប់វិនិយោគ និងការគាំទ្របច្ចេកទេសមានការថមថយកាន់តែខ្លាំង ដែលជះឥទ្ធិពលដល់គុណភាពអប់រំ។ បរិការណ៍នៃការរាតត្បាតនៃជំងឺកូវីដ ១៩ ថវិកាគ្រោងសម្រាប់ឆ្នាំ២០២១នេះ ជាទិសដៅបន្តរក្សានូវការគាំទ្រលើការពង្រឹងគុណភាព និងសេវាអប់រំដែលរងផលប៉ះពាល់ក្នុងរយៈពេលជាង៩ខែកន្លងមកនេះ។ ប្រទេសកម្ពុជាកំពុងប្រឈមនឹងបញ្ហានានាក្នុងការទទួលបានការអប់រំ និងការរៀនសូត្រតាំងពីមុនពេលនៃការរីករាលដាលនូវជំងឺរាតត្បាតកូវីដ ១៩ ឧទាហរណ៍ ៣៧% នៃកុមារដែលមានអាយុ ៥ ឆ្នាំ មិនបានចុះឈ្មោះក្នុងការអប់រំណាមួយឡើយ[1]។ លើសពីនេះទៅទៀតកុមារអាយុ៣ឆ្នាំ ប្រមាណ ៧៨% មិនមានលទ្ធភាពទទួលបានការអប់រំ និងបរិស្ថានផ្ទះនៅតាមតំបន់ជនបទដែលជារឿយៗខ្វះខាតសម្ភារៈសិក្សាសៀវភៅឬប្រដាប់ប្រដាក្មេងលេង[2]។ សាលារៀនទាំងអស់ត្រូវបានបិទនៅខែមីនា ឆ្នាំ២០២០ នាំឱ្យសិស្សានុសិស្សប្រមាណ ៣.១ លាននាក់មិនបាន

[1] Ministry of Education, Youth and Sports, (2019). The Education, Youth, and Sport Performance in the Academic Year 2017 – 2018 and Goals for the Academic Year 2018 – 2019, p. 31.
[2] Ministry of Education, Youth and Sports, (2019). The Education, Youth, and Sport Performance in the Academic Year 2016 – 2017 and Goals for the Academic Year 2017 – 2018, p. 24.

សិក្សារៀនសូត្រ[3]។ ការទទួលបានការរៀនសូត្រ ពីចម្ងាយនៅមានកម្រិតនៅឡើយក្រោយពីរងផលប៉ះពាល់នៃជម្ងឺរាតត្បាត ១៩ ជាពិសេសនៅតាមតំបន់ជនបទ ដែលមានប្រជាជនរហូតដល់ ៨០% នៃប្រជាជនកម្ពុជាសរុបដែលពួកគេរស់នៅជនបទ ហើយមានតែកុមារកុមារ ១១% នៅតំបន់ជនបទទំនងជាចូលរួមកម្មវិធីអប់រំកុមារតូចបើប្រៀបធៀបនឹងកុមារ ៣៦% នៅតំបន់ទីក្រុង[4]។ ទោះបីកុមារប្រមាណ៧០% នៃកុមារដែលបានចូលរួមក្នុងការអង្កេត មកពីគ្រប់កម្រិតសិក្សាទាំងអស់ បានរាយការណ៍ថា ពួកគេបានរៀនសូត្រពីចម្ងាយ (distance learning) តាមទម្រង់ណាមួយ ដូចជា វីឌីអូរបស់ក្រសួងផ្សព្វផ្សាយតាមបណ្តាញសង្គម ឯកសារកិច្ចការ ឬកម្មវិធីរៀនអនឡាញ ដែលសាលាពួកគេរៀបចំ និងកម្មវិធីទូរទស្សន៍ ប៉ុន្តែមាន១៦% នៃពួកគេបានចំណាយពេលច្រើន៥ម៉ោង ២៦%ចំណាយពេល ១ ទៅ៣ម៉ោង និង៣៧% ចំណាយពេល ៣០នាទី ទៅ១ម៉ោងក្នុងមួយសប្តាហ៍ ម្យ៉ាងទៀតពួកគេជួបឧបសគ្គនៅក្នុងការរៀនសូត្រ ដូចជា ៥១% ដោយសារតែការការចំណាយលើអ៊ីនធ័រណែត ឬឧបករណ៍រៀនតាមអនឡាញ និង ៤៣% បញ្ហាការភ្ជាប់បណ្តាញអ៊ីនធ័រណែត[5]។ ដោយឡែកកុមារ៉ា ១៧% និងកុមារី ១៤% ពួកគេប្រឈមនឹងការបោះបង់ការសិក្សា ក្នុងនោះ១៩% គឺជាកុមារក្នុងគ្រួសារដែលកំណត់ក្នុងអត្តសញ្ញាណក្រីក្រ (ID Poor) ធៀបនឹងកុមារមិនស្ថិតក្នុងអត្តសញ្ញាណក្រីក្រ តែ១៥%)[6]។

យោងតាមទិន្នន័យនៃការស្រាវជ្រាវ និងវិភាគខាងលើនេះ អង្គការសង្គមស៊ីវិលសូមស្នើរាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណានូវ អនុសាសន៍/សំណូមពរដូចមានរៀបរាប់ខាងក្រោមនេះ៖

១. ធានានិងពង្រីកវិសាលភាពគ្របដណ្តប់និងសេវាគាំពារសង្គមដើម្បីទ្រទ្រង់ដល់គ្រួសារដែលទទួលរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ជាពិសេសគ្រួសារក្រីក្រ និងអ្នកថែទាំដែលបាត់បង់ការងារ ឬប្រាក់ចំណូលក្នុងគ្រួសារក្នុងកំឡុងពេលនៃជំងឺកូវីដ ១៩ ដើម្បីជួយដល់ក្រុមដែលងាយរងគ្រោះបំផុត។ កុមារដែលប្រឈមនឹងការបោះបង់ការសិក្សាដោយទទួលបានការអប់រំ ជាពិសេសកុមារី និងកុមារមានពិការភាពនៅតាមតំបន់ដាច់ស្រយាល។

២. ធានាថាការរៀនសូត្រពីចម្ងាយមានប្រសិទ្ធភាព ត្រូវផ្តល់នូវជម្រើស និងយុទ្ធសាស្រ្តគាំទ្រតួនាទីរបស់ឪពុកម្តាយក្នុងការរៀនសូត្ររបស់កុមារនៅផ្ទះតាមរយៈការលើកកម្ពស់ការអភិវឌ្ឍធនធាន និងសកម្មភាពគាំទ្រកូនៗរបស់ពួកគេនៅផ្ទះ។

៣. ពង្រឹងទៅលើការអប់រំនៅតាមប្រព័ន្ធអ៊ីនធឺណែត ឬរៀនសូត្រពីចម្ងាយ និងធានានូវគុណភាព ជាពិសេសធ្វើឱ្យប្រាកដថា កុមារទាំងអស់ទទួលបានការអប់រំក្នុងកំឡុងពេលរីករាលដាលនៃវីរុសកូវីដ១៩ ជាពិសេសកម្មវិធីអប់រំកុមារតូច។ បង្កើតឲ្យមានកម្មវិធីអប់រំតាមទូរសទ្សន៍ និងវិទ្យុ កុមារថ្នាក់ទី១ដល់ទី៦ បង្កើនការរៀនសូត្រពីចម្ងាយលើមុខវិជ្ជាខ្មែរ និងគណិតវិជ្ជា ហើយថ្នាក់ទី៧ ដល់ទី១២ ផ្តោតលើមុខវិជ្ជាគោលទាំង៦។ ព្រមទាំងពង្រឹងសមត្ថភាពបុគ្គលិកអប់រំ និងគ្រូ ដើម្បីត្រៀមសម្រាប់ឆ្នាំសិក្សាថ្មី បច្ចេកទេសប្រើប្រាស់បច្ចេកវិទ្យាសម្រាប់បង្រៀនពីចម្ងាយ និងគាំទ្របន្ថែមចំពោះកុមារដែលងាយរងគ្រោះនៃការបោះបង់ការសិក្សា។

---

[3] Save the Children Asia, (2020). COVID – 19 response strategy May 2020 – December 2021, p.2.
[4] National Institute of Statistics, (2015). Cambodia Demographic and Health Survey 2014, p 165.
[5] COVID-19 Joint Education Sector Needs Assessment commissioned by the MoEYS and ESWG (Nov, 2020).
[6] Idib

៤. បង្កូ និងលើកកម្ពស់កិច្ចសហការគ្នារវាងកិច្ចការអប់រំចំណេះទូទៅ អប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឲ្យមានភាពស៊ីសង្វាក់ និងឆ្លើយតបតម្រូវការទីផ្សារការងារ គួរមានការរក្សាការបង្កើនថវិកាគ្រោងសម្រាប់វិស័យនេះឲ្យមានកម្រិតខ្ពស់ឡើងជាលំដាប់និងលើកកម្ពស់យន្តការត្រួតពិនិត្យវាយតម្លៃ និងគាំទ្រខាងបច្ចេកទេសសមស្រប។

**កិច្ចការសង្គមកិច្ច (ការការពារកុមារ)**

រាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកា សម្រាប់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រមាណ ៥.៩% (២០១៩) និង ៦.៣% (២០២០) និងបន្តកើតឡើង ៦.៩% (២០២១) ធៀបនឹងថវិកាសរុបជាតិចរន្ត។ កំណើននៃថវិកាវិភាជនេះបានឆ្លុះបញ្ចាំងអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនៃការប៉ះពាល់ក្នុងបរិការណ៍នៃការរាតត្បាតនៃជំងឺកូវីដ១៩។ ថវិកាគ្រោងឆ្លើយតបការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ដោះស្រាយជីវភាពចំពោះជនក្រីក្រ ជាពិសេសកម្មភាពគាំពារសង្គម (គាំទ្រការថែទាំសុខភាពសម្រាប់កម្មករ ឧបត្ថម្ភភាពសម្រាប់កម្មករនិយោជិត បន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច និងថវិការត្រៀមអន្តរគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ១៩ពិសេសកម្មវិធីឧបត្ថម្ភគ្រួសារក្រីក្រ (ក្រ១ និងក្រ២) ប្រមាណ២០០លានដុល្លារ។

ការរាតត្បាតនៃជំងឺកូវីដ ១៩ បានធ្វើប៉ះពាល់ដល់ទំនាក់ទំនងគ្រួសារនិងសុខមាលភាពរបស់កុមារ។ យើងមានការព្រួយបារម្ភចំពោះហានិភ័យនៃកិច្ចការការពារកុមារ ដូចជាអំពើហឹង្សាលើកុមារ អាពាហ៍ពិពាហ៍កុមារ និងពលកម្មកុមារអាចនឹងកើនឡើងដោយសារតែការបិទទ្វារសាលារៀន អំឡុងពេលមានជំងឺរាតត្បាត ដូច្នេះមានតំរូវការចាំបាច់ដើម្បីធានាបាននូវប្រព័ន្ធការពារកុមារ និងសេវាសង្គមកិច្ចជាបន្តបន្ទាប់ក្នុងពេលមាននៃការរាតត្បាតនៃជំងឺកូវីដ១៩ ជាពិសេសសំរាប់កុមារងាយរងគ្រោះ។

ជាមួយគ្នានេះថវិកាវិភាជ មានកម្រិតតិចតួចនៅឡើយសម្រាប់ក្រសួងកិច្ចការនារី ប្រមាណ0.៣% ក្នុងឆ្នាំ ២០២០[7]។ ក្រសួងកិច្ចការនារី មានផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ និងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ដើម្បីឆ្លើយតបនឹងការលុបបំបាត់វិសមភាពយេនឌ័រ អំពើហិង្សាផ្អែកលើយេនឌ័រ និងការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ ពិសេសកុមារី។ យុទ្ធសាស្ត្រជាតិការអប់រំបែបវិជ្ជមានដែលមានក្នុងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ដែលផ្តល់ការគាំទ្រ និងអន្តរាគមន៍ដល់ឪពុកម្តាយ/អ្នកថែទាំ ដើម្បីបង្កើនជំនាញដោះស្រាយបញ្ហារបស់ពួកគេក្នុងការប្រាស្រ័យទាក់ទងដោយអហិង្សា ការដោះស្រាយទំនាស់ និងបំណិនជីវិត ឈានទៅដល់លើកកម្ពស់សមភាពយេនឌ័រ ការទំនាក់ទងអហឹង្សា និងលុបបំបាត់អំពើហិង្សាលើកុមារពីសំណាក់ឪពុកម្តាយ/អ្នកថែទាំ។

យោងតាមទិន្នន័យនៃការស្រាវជ្រាវ និងវិភាគខាងលើនេះ អង្គការសង្គមស៊ីវិលសូមស្នើរាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណានូវ អនុសាសន៍/សំណូមពរដូចមានរៀបរាប់ខាងក្រោមនេះ៖

[7] តួលេខឆ្នាំ២០២១ មិនមានបង្ហាញនៅក្នុង ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេ។

១. រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរបន្តកិច្ចខិតខំប្រឹងប្រែងដោយ វិភាជថវិកាបន្ថែមសម្រាប់ឆ្លើយតបកិច្ចការពារកុមារ ដើម្បីៈ

- ធានាថាប្រព័ន្ធរបាយការណ៍កិច្ចការពារកុមារ និងប្រព័ន្ធបញ្ជូន កែសម្រួល និងឆ្លើយតបគ្រប់ជ្រុងជ្រោយ សម្រាប់ពេលវេលានៃការបិទសាលារៀន និងពេលសាលារៀនបើកទ្វារឡើងវិញ ដើម្បីគាំទ្រដល់កុមារដែលអាចប្រឈមនឹងភាពតានតឹងពេលនៅផ្ទះអំឡុងពេលមានជំងឺរាតត្បាត ជំងឺកូវីដ១៩ ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ។
- ធានាសេវាកម្មគាំទ្រ ផ្នែកចិត្តសាស្ត្រសង្គម និងផ្តល់នូវជំនាញមូលដ្ឋានអំពីសេវាគាំទ្រចិត្តសង្គមដល់បុគ្គលិកអប់រំ ដើម្បីអាចកំណត់អត្តសញ្ញាណ និងបញ្ជូនកុមារដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតពីវិបត្តិនេះទៅសេវាការពារកុមារ និងសេវាសុខភាពផ្លូវចិត្ត ជាពិសេសកុមារទាំងនោះដែលរងផលប៉ះពាល់ដោយភាពតាន ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ ក្នុងកំឡុងពេល និងក្រោយពេលនៃជំងឺរាតត្បាតជំងឺកូវីដ ១៩។

២. រាជរដ្ឋាភិបាលកម្ពុជា គួរវិភាជថវិកាបន្ថែម សម្រាប់ក្រសួងកិច្ចការនារី ដើម្បីបង្កើនលទ្ធភាពអន្តរគមន៍ឆ្លើយតបអំពើហិង្សាលើស្ត្រី និងកុមារ ជាពិសេស យុទ្ធសាស្ត្រស្តីពីការអប់រំបែបវិជ្ជមានដែលមានក្នុងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) ដើម្បីធានាបាននូវការអប់រំសម្រាប់ឪពុកម្តាយ/អ្នកថែទាំកុមារ អំពីវិធីអប់រំកូនៗ របស់ពួកគេដោយគ្មានហិង្សា ការបង្កើនការយកចិត្តទុកដាក់ជាមួយកូនៗ និងការបង្រៀនកូននៅផ្ទះ ក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ១៩និងការរៀតសូត្រពីចម្ងាយ

## ៤. ការចំណាយតាមក្រសួង និងស្ថាប័ន



ប្រភពៈ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

យោងទៅលើខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ យើងបានឃើញថា ក្រសួងអប់រំ យុវជន និងកីឡា នៅតែដើរតួនាទីសំខាន់ និងអាទិភាពជាងគេបំផុត ក្នុងចំណោមក្រសួងស្ថាប័នរដ្ឋផ្សេងៗ។ ការគ្រោងថវិកាឆ្នាំ ២០២១ សម្រាប់ក្រសួងនិងស្ថាប័នរដ្ឋ គឺត្រូវបានគ្រោងថវិកាច្រើនជាងគេទៅលើក្រសួងអប់រំ យុវជន និងកីឡា ដែលមានចំនួន ៣.៤៣៦.២៦៣ លានរៀល ស្មើនឹង ១០,៧៣% នៃគ្រោង ថវិកាជាតិសរុប បង្ហាញពីគម្លាតកាន់តែធំឡើងបើធៀបនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ (គោលដៅទី៤)។ ក្រសួងការពារជាតិ ត្រូវបានគ្រោងថវិកាច្រើនបន្ទាប់ ដែលមានចំនួន ២.៥៦៥.៨៦២ ស្មើនឹង ៨,០២% នៃថវិកាជាតិសរុប។ ក្រៅពីនោះក្រសួងមហាផ្ទៃបានគ្រោងថវិកាចំនួន ២.០៣១.៩៧៤លានរៀល ស្មើនឹង៦,៣៥% នៃថវិកាជាតិសរុប។ សង្គមស៊ីវិលមើលឃើញថាវិស័យនីមួយៗហាក់មានការធ្លាក់ចុះបើប្រៀបធៀបជាមួយនឹងច្បាប់ឆ្នាំ២០២០។

**អង្គការសង្គមស៊ីវិល សូមស្នើក្រសួងស្ថាប័នទាំងអស់ចូលរួមកាត់បន្ថយនូវចំណាយណាដែលមិនចាំបាច់ និងសូមលើកទឹកចិត្ត រាជរដ្ឋាភិបាល កៀរគរ សង្គមស៊ីវិល និងវិស័យឯកជនចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍។ សង្គមស៊ីវិល គាំទ្រចំពោះបទអន្តរាគមន៍ទាក់ទងនឹងជំងឺកូវីដ ១៩ ក្នុងនោះក៏សូមស្នើរាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាល ជួយគិតគូបន្ថែមទៀតលើជំងឺមិនឆ្លង។ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាល និងរដ្ឋសភា ពិចារណាលើការវិភាជថវិកាសម្រាប់វិស័យអប់រំ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ គួរត្រូវបានបង្កើន លើសពីឆ្នាំមុនៗ ដោយបង្កើត និងបង្កើនអន្តរកម្មរវាងវិស័យទាំងពីរនេះ ដើម្បីវិស័យនេះមានលទ្ធភាពបង្កើតកម្មវិធីសិក្សា និងវិធីសាស្ត្ររៀននិងបង្រៀនថ្មីៗ ឆ្លើយតបនឹងតម្រូវការលើកកម្ពស់ការត្រួតពិនិត្យវាយតម្លៃ និងផ្តល់កិច្ចគាំពារបច្ចេកទេសនានាបន្ថែម។**

## ៥. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតាលានរៀល) | ២០២០ ច្បាប់ | ២០២០ % ផសស | ២០២១ គ្រោង | ២០២១ % ផសស | % កំណើន |
|---|---|---|---|---|---|
| ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ | 2,243,778 | 2.03% | 1,518,406 | 1.29% | -32.3% |
| • *ចំណូលសារពើពន្ធ* | 2,086,308 | 1.89% | 1,050,323 | 0.89% | -49.7% |
| • *ចំណូលមិនមែនសារពើពន្ធ* | 157,470 | 0.14% | 468,083 | 0.40% | 197.3% |
| សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ | 3,329,236 | 3.01% | 2,578,856 | 2.19% | -22.5% |
| • *ចំណាយចរន្ត* | 2,866,880 | 2.59% | 2,364,650 | 2.00% | -17.5% |
| • *ចំណាយមូលធន* | 462,356 | 0.42% | 214,206 | 0.18% | -53.7% |
| ឱនភាពថវិកា | -1,085,458 | -0.98% | -1,060,450 | -0.90% | -2.3% |
| ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ | 1,085,458 | 0.98% | 1,060,450 | 0.90% | -2.3% |
| • *រាជធានី-ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ)* | 47,024 | 0.04% | 12,807 | 0.01% | -72.8% |
| • *ក្រុង-ស្រុក* | 235,117 | 0.21% | 338,095 | 0.29% | 43.8% |
| • *ឃុំ-សង្កាត់* | 607,386 | 0.55% | 540,608 | 0.46% | -11.0% |
| • *មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់* | 195,931 | 0.18% | 168,940 | 0.14% | -13.8% |

ប្រភព៖ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ បានប៉ាន់ស្មានថានឹងមានកំណើនក្នុងអាត្រា -១,៩% ក្នុងពេលដែលការវាយតម្លៃឡើងវិញរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នាពេលថ្មីៗនេះបានខិតមកជៀកនឹងកម្រិតអវិជ្ជមានជាង-២%។ ដោយឡែក សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១ ត្រូវបានព្យាករណ៍ថា នឹងងើបឡើងវិញ ហើយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់ ៣,៥% ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ ១១៧ ៩៣៩ ប៊ីលានរៀល, សមមូលនឹងប្រមាណ ២៩ ០១៣ លានដុល្លារអាមេរិក, ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៧៧១ ដុល្លារអាមេរិក បើប្រៀបធៀបនឹង ១ ៦៨៣ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។

ថវិកា រាជធានី ខេត្ត ស្រុក ខណ្ឌ និង ឃុំសង្កាត់ គឺកាន់តែតិចប្រៀបធៀបទៅនឹងកម្រិតថ្នាក់ជាតិដោយសារតែចំណូលចរន្តបានតិចនៅឆ្នាំ ២០២០ ដែលធ្វើឱ្យការផ្ទេរថវិកាសម្រាប់មូលនិធិ ទាំងនេះមានចំនួនតិចនៅឆ្នាំ ២០២១។ វាអាចនឹងមានប្រក្រតីភាពនៅឆ្នាំ២០២២ វាអាស្រ័យនឹងកំណើនសេដ្ឋកិច្ច។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់បន្ថែមនូវមូលនិធិឃុំសង្កាត់ (ផ្នែកអភិវឌ្ឍន៍) ប្រមាណ១% នៃកម្រិតចំណូលជាតិសម្រាប់ឆ្នាំ ២០២១។ សម្រាប់ រាជធានី ខេត្ត ស្រុក ខណ្ឌ ការបង្កើនថវិការបស់ពួកគេគឺដោយសារតែការផ្ទេរថវិកា (ផ្ទេរចេញពីថវិកាមន្ទីរខេត្ត ទៅ ស្រុក ខណ្ឌ សម្រាប់ការិយាល័យ និងបុគ្គលិកផ្ទេរដែលមានចំនួនប្រមាណ ៨២ ប៊ីលានរៀល / ២០ លានដុល្លារ។

សម្រាប់ថ្នាក់រាជធានីខេត្ត គឺមានចំណូលរបស់ខ្លួន (ពន្ធ និងមិនមែនសារពើពន្ធ)។គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និងឃុំ-សង្កាត់ខាងលើបានធ្វើឱ្យមានឱនភាពថវិកាចំនួន ១០៦០ ៤៥០ លានរៀលត្រូវជា ០,៩០% នៃផសស ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាជាតិ ដែលការឧបត្ថម្ភថយចុះ ២,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២០។ ជាមួយនឹង ឱនភាពថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាចំនួន១ ២៨០៧លានរៀល សម្រាប់រដ្ឋបាលស្រុក-ខណ្ឌដើម្បីអនុវត្តការផ្ទេមុខងាររបស់មន្ទីរជំនាញ និងថវិកាចំនួន ១៦៨ ៩៤០ លានរៀល, ថយចុះ១១,០% ធៀបនឹងច្បាប់ឆ្នាំ២០២០ សម្រាប់ឧបត្ថម្ភឃុំ-សង្កាត់ ឱនភាពទាំងនេះនឹងអាចធ្វើឱ្យមានផលប៉ះពាល់ដល់ការបំពេញមុខងាររបស់មន្ទីរជំនាញ រដ្ឋបាលឃុំ-សង្កាត់ ក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ ជនមានពិការភាព ចាស់ជរា និងកុមារជាដើមនៅកម្រិតរដ្ឋបាលខណ្ឌ និងឃុំ-សង្កាត់។

បណ្តារដ្ឋបាលថ្នាក់ក្រោមជាតិដែលកំពុងធ្វើកំណែទម្រង់វិមជ្ឈការ និងទទួលការផ្ទេរតួនាទីនឹងជួបបញ្ហាប្រឈមចំពោះឱនភាពថវិកានេះ។ មួយវិញទៀត ផែនការ និងកម្មវិធីសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី/ខេត្តនឹងមិនឆ្លើយតបនឹងតម្រូវការ និងបញ្ហារបស់ប្រជាពលរដ្ឋបានឡើយ។ យ៉ាងណាមិញ ឱនភាពថវិកាសម្រាប់រដ្ឋបាលឃុំ-សង្កាត់នឹងមានផលប៉ះពាល់ផងដែរដល់ការបំពេញមុខងាររបស់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ (គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចនារី និងកុមារឃុំ-សង្កាត់ (គ.ក.ន.ក) ក្នុងការផ្តល់សេវាសង្គមសម្រាប់ប្រជាពលរដ្ឋជាពិសេសស្ត្រី និងកុមារ។ បញ្ហាមួយទៀត គឺទាក់ទងទៅផលវិបាក នៃការធ្វើចំណាត់ថ្នាក់ថវិកាសម្រាប់ការអភិវឌ្ឍបែបអរូបវ័ន្ត ឬសេវាសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជាមួយនឹងឱនភាព និងការព្រួយបារម្ភទាំងនេះ អង្គការសង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាល ធ្វើចំណាត់ថ្នាក់សម្រាប់ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ជាពិសេសផ្តោតលើការប្រើប្រាស់ថវិកាសម្រាប់ការអនុវត្តមុខងាររបស់ គ.ក.ស.ក និងគ.ក.ន.ក ក្នុងការផ្តល់សេវាសង្គមសម្រាប់ប្រជាពលដ្ឋជាពិសេសស្ត្រី ជនមានពិការភាព និងកុមារ។ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិគួរផ្តោតលើការបំពេញមុខងាររបស់មន្ទីរជំនាញដែលបានទទួលការផ្ទេរមុខងារពីថ្នាក់ជាតិផងដែរ។ ជាមួយគ្នានេះ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់អាទិភាពផងដែរ ចំពោះការអនុវត្តមុខងាររបស់សេវាច្រកចេញចូលតែមួយប្រកបដោយគុណភាព និងបែងចែកថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមជំហានទី២ ដោយជោគជ័យនិងពង្រឹងភាពជាម្ចាស់របស់រដ្ឋាភិបាល។ សូមបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាពិសេសជនដែលងាយរងគ្រោះនៅក្នុងដំណើររៀបចំផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានប្រសើរឡើង និងធានាបាន គណនេយ្យភាពនៅក្នុងការផ្តល់នូវសេវាសាធារណៈ។**

## ៦. ស្ថានភាពបំណុល




ប្រភព៖ ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

យោងតាមខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ បានឱ្យដឹងថា រាជរដ្ឋាភិបាល បានកំណត់ពិដានក្នុងការខ្ចីយ៉ាងច្រើន សម្រាប់ឆ្នាំ ២០២១ ក្នុងកម្រិត ១៥០០លានអេសដេអ៊ែរ ដើម្បីស្តារនិងជំរុញសេដ្ឋកិច្ច ឡើងវិញឆ្លើយតបនឹងបរិការណ៍ពីផលប៉ះពាល់ការរីករាលដាលនៃជំងឺកូវីដ ១៩ និងដើម្បីទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ច រយៈពេលមធ្យម និងវែងដែលផ្តត់ផ្តង់ទៅលើ វិស័យថាមពល ធារាសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងវិស័យអាទិភាពផ្សេងៗ។

សង្គមស៊ីវិលសូមស្នើរាជរដ្ឋាភិបាលគ្រប់គ្រងបំណុលប្រកបដោយតម្លាភាព និងគណនេយ្យភាពនិងអាទិភាពទៅលើវិស័យ ដែលទ្រទ្រង់នូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍនូវជំនាញវិជ្ជាជីវៈ ដល់ប្រជាពលរដ្ឋ ដែលបាត់បង់ការងារធ្វើ ព្រមទាំងគិតគូរដល់ការវិនិយោគក្នុងស្រុក។

## ៧. សេចក្តីសន្និដ្ឋាន និងសំណូមពរ

ការសង្ខេប និងវិភាគខាងលើ គឺផ្អែកលើទិន្នន័យទាំងស្រុងនៃ "ខ្លឹមសារសង្ខេបប្រតិបត្តិ ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១" ចេញផ្សាយលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០។ អង្គការសង្គមស៊ីវិល សូមធ្វើការវាយតម្លៃខ្ពស់របស់រាជរដ្ឋាភិបាលជាពិសេសស្ថាប័នក្រសួងសាមី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងផ្សព្វផ្សាយនូវឯកសារនេះ ដែលរដ្ឋសភាជាតិ គ្រោងនឹងដាក់ពិភាក្សា និងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។ អង្គការសង្គមស៊ីវិល សំណូមពរឱ្យរាជរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយ និងផ្តល់សេចក្តីព្រាងច្បាប់ថវិកាពេញលេញ សម្រាប់ប្រជាពលរដ្ឋ និងបង្កើតឱ្យមានកិច្ចពិភាក្សា រវាងរដ្ឋសភា ក្រសួង ប្រជាពលរដ្ឋ និង អង្គការសង្គមស៊ីវិល ដើម្បីបន្តចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងតម្លាភាពថវិកាដែលជាផ្នែកមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបង្កើតយន្តការសាកល្បងដើម្បីចូលរួមជាសាធារណៈក្នុងអំឡុងពេលកសាងផែនការថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលគួរបង្កើតវេទិការឬយន្តការទៀងទាត់មួយសម្រាប់សាធារណជនចូលរួមវិភាគទានជាបដិមតិក្នុងន័យស្ថាបនាក្នុងដំណើរការត្រួតពិនិត្យការអនុវត្តថវិកាដែលបានអនុម័តរួច។